# វេទិកាស្តីពី
# ភាពស្របច្បាប់នៃការគ្រប់គ្រងសហគមន៍ព្រៃឈើ និង
# ការចូលរួមពីស្ថាប័នពាក់ព័ន្ធ ក្នុងការគ្រប់គ្រងសហគមន៍ព្រៃឈើ

**សាលប្រជុំនៃសណ្ឋាគារ កំពង់ធំរ៉ូយ៉ាល់ ខេត្តកំពង់ធំ**

ថ្ងៃព្រហស្បតិ៍ ១រោច ខែមាឃ ឆ្នាំឆ្លូវ ត្រីស័ក ពុទ្ធសករាជ ២៥៦៥

ថ្ងៃ១៧ ខែកុម្ភៈ ឆ្នាំ២០២២

## ១. សាវតា និងការប្រឈមក្នុងការគ្រប់គ្រងសហគមន៍ព្រៃឈើ

ការគ្រប់គ្រងសហគមន៍ព្រៃឈើ (ស.ព) គឺជាកម្មវិធីទី៤ នៃកម្មវិធីព្រៃឈើជាតិកម្ពុជា ២០១០-២០២៩ ដែល សម្របសម្រួល និងអនុវត្តដោយរដ្ឋបាលព្រៃឈើនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ គោលបំណងសំខាន់នៃកម្មវិធីព្រៃឈើជាតិ គឺដើម្បីចូលរួមចំណែកក្នុងការកាត់បន្ថយភាពក្រីក្រតាមរយៈការគ្រប់គ្រងធនធានព្រៃឈើ និងសត្វព្រៃប្រកបដោយនិរន្តភាពដោយសហគមន៍មូលដ្ឋាន។

ផ្អែកតាមស្ថិតិសហគមន៍ព្រៃឈើជាតិឆ្នាំ២០១៩ នៅទូទាំងប្រទេសមាន ស.ព ចំនួនសរុប ៦៣៦ កន្លែង គ្របដណ្តប់លើផ្ទៃដី ៥១៦.៨១៧ ហិកតា និងមានការចូលរួមពីប្រជាជននៅមូលដ្ឋានចំនួន១៦៩.២៤៨គ្រួសារ។ ស.ព ទាំងអស់នេះស្ថិតនៅក្នុងជំហាននៃការអភិវឌ្ឍផ្សេងៗគ្នា ក្នុងនោះមាន៖ ស.ព ៤៨៤កន្លែង ទទួលបានប្រកាសពីក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ, ស.ព ៤៣៩កន្លែង បានចុះកិច្ចព្រមព្រៀងរវាងនាយខណ្ឌរដ្ឋបាលព្រៃឈើ និងគណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើ, និង ស.ព ៨៥កន្លែង ស្ថិតក្នុងខេត្តចំនួន៦ គឺខេត្តកំពង់ធំ ក្រចេះ ស្ទឹងត្រែង ពោធិ៍សាត់ កំពង់ឆ្នាំង កំពង់ស្ពឺ និងបាត់ដំបង ទទួលបានការយល់ព្រមពីខណ្ឌរដ្ឋបាលព្រៃឈើ លើផែនការគ្រប់គ្រងព្រៃសហគមន៍។

ការគ្រប់គ្រងសហគមន៍ព្រៃឈើត្រូវបានអនុវត្តស្របទៅតាមច្បាប់ស្តីពីព្រៃឈើឆ្នាំ២០០២ អនុក្រឹត្យស្តីពីការគ្រប់គ្រងសហគមន៍ព្រៃឈើឆ្នាំ២០០៣ និងប្រកាសស្តីពីគោលការណ៍ណែនាំអំពីសហគមន៍ព្រៃឈើ ឆ្នាំ២០០៦។ ដើម្បីគ្រប់គ្រង ស.ព ស្របទៅតាមលិខិតបទដ្ឋាន ច្បាប់ទាំងនេះ តម្រូវឲ្យមានការចូលរួមពីស្ថាប័នពាក់ព័ន្ធ ជាពិសេសអាជ្ញាធរមូលដ្ឋាន ហើយលើសពីនេះទៅទៀត នៅពេលដែលមានទំនាស់ធ្ងន់ធ្ងរដែលមិនអាចសម្របសម្រួលដោះស្រាយបានដោយស្ថាប័នជំនាញ និងអាជ្ញាធរ គេត្រូវការស្ថាប័នតុលាការ ដើម្បីដោះស្រាយស្របទៅតាមនីតិវិធីច្បាប់។

បច្ចុប្បន្ននេះការប្រឈមមួយដ៏ធំ ក្នុងការគ្រប់គ្រងសហគមន៍ព្រៃឈើ គឺការទន្ទ្រានកាន់កាប់ដីព្រៃសហគមន៍ ដើម្បីធ្វើជាកម្មសិទ្ធិ ដែលករណីមួយចំនួនបានសម្របសម្រួលដោះស្រាយនៅក្រៅប្រព័ន្ធតុលាការ ដោយមានអន្តរាគមន៍ពីរដ្ឋបាលព្រៃឈើ និងអាជ្ញាធរមូលដ្ឋាន ប៉ុន្តែក៏មានករណីមួយចំនួនដែលមិនអាចដោះស្រាយបាន ហើយត្រូវបានកសាងសំណុំរឿងដាក់ទៅតុលាការ ក្នុងនោះផងដែរក៏មានករណី គណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើត្រូវបានជាប់បណ្តឹងនៅតុលាការ ក្នុងបុព្វហេតុការពារដីព្រៃសហគមន៍ដែលជា សម្បត្តិអចិន្ត្រៃយ៍របស់រដ្ឋ។ ការប្រឈមទាំងនេះត្រូវបានលើកឡើងដោយបណ្តាញសហគមន៍ព្រៃឈើ នៅក្នុងកិច្ចប្រជុំគណៈកម្មការសម្របសម្រួលកម្មវិធីសហគមន៍ព្រៃឈើខេត្តកំពង់ធំកាលពីថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២១។ ឆ្លើយ

តបទៅនឹងការលើកឡើងរបស់បណ្តាញសហគមន៍ព្រៃឈើ គណៈកម្មការសម្របសម្រួលកម្មវិធីសហគមន៍ព្រៃឈើខេត្ត បានផ្តួចផ្តើមឲ្យរៀបចំនូវវេទិការ ស្តីពី ភាពស្របច្បាប់នៃការគ្រប់គ្រងសហគមន៍ព្រៃឈើ និងការចូលរួមពីស្ថាប័ន ពាក់ព័ន្ធក្នុងការគ្រប់គ្រងសហគមន៍ព្រៃឈើនេះឡើង ដើម្បីបន្ធូរបន្ថយនូវការប្រឈម និងដើម្បីធានាបាននូវនិរន្តរភាពនៃការគ្រប់គ្រងសហគមន៍ព្រៃឈើ ។

អង្គការ RECOFTC តាមរយៈគម្រោងភាពជាដៃគូលើវិស័យព្រៃឈើ និងផលផលនៅកម្ពុជា ដំណាក់កាលទី ៣ (PaFF3) ក្រោមជំនួយថវិកាពី ទីភ្នាក់ងារសំរាប់ការអភិវឌ្ឍន៍ និងសហប្រតិបត្តិការស្វីស (SDC) និងទីភ្នាក់ងារស៊ុយអែតសម្រាប់កិច្ចសហប្រតិបត្តិការអភិវឌ្ឍអន្តរជាតិ (Sida) និងគម្រោង លើកកម្ពស់ការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព ដើម្បីបង្កើនភាពស៊ាំដល់សហគមន៍នៅក្នុងផែនទេសភាពព្រៃឡង់ ក្រោមជំនួយខ្នាតតូចនៃគម្រោងព្រៃឡង់បៃតង សហការជាមួយស្ថាប័នពាក់ព័ន្ធ តាមរយៈគណៈកម្មការសម្របសម្រួលកម្មវិធីសហគមន៍ព្រៃឈើខេត្ត រៀបចំវេទិការនេះឡើង ដើម្បីបង្កើនប្រសិទ្ធិភាពនៃការចូលរួមគ្រប់គ្រងសហគមន៍ព្រៃឈើ និងធានាបាននូវចីរភាពនៃការគ្រប់គ្រងសហគមន៍ព្រៃឈើ។

## ២. គោលបំណង

វេទិការស្តីពីភាពស្របច្បាប់នៃការគ្រប់គ្រងសហគមន៍ព្រៃឈើ និង ការចូលរួមពីស្ថាប័នពាក់ព័ន្ធ ក្នុងការគ្រប់គ្រងសហគមន៍ព្រៃឈើ រៀបចំឡើងក្នុងគោលបំណងដើម្បី៖

- ស្ថាប័នពាក់ព័ន្ធស្វែងយល់ស៊ីជម្រៅអំពីភាពស្របច្បាប់នៃការគ្រប់គ្រងសហគមន៍ព្រៃឈើ
- ពិភាក្សាស្វែងរកយុទ្ធសាស្ត្រ ដើម្បីបង្កើនការចូលរួមពីស្ថាប័នពាក់ព័ន្ធ ដើម្បីកាត់បន្ថយនូវការប្រឈមនានាក្នុងការការពារព្រៃសហគមន៍

## ៣. ទីកន្លែង និងពេលវេលា

- បន្ទប់ប្រជុំនៃសណ្ឋាគារកំពង់ធំរ៉ូយ៉ាល់
- ថ្ងៃទី ១៧ ខែកុម្ភៈ ឆ្នាំ ២០២២

## ៤. អ្នកចូលរួម

វេទិការនេះ នឹងមានអ្នកចូលរួម ៨២នាក់ រួមមានមកពី នាយកដ្ឋានព្រៃឈើ និងសហគមន៍ព្រៃឈើ ការិយាល័យសហគមន៍ព្រៃឈើ នៃរដ្ឋបាលព្រៃឈើ នាយកដ្ឋានជីវភាពសហគមន៍ និងនាយកដ្ឋានទេសចរណ៍ធម្មជាតិ អគ្គនាយកដ្ឋានសហគមន៍មូលដ្ឋាន នៃក្រសួងបរិស្ថាន គណៈកម្មការសម្របសម្រួលកម្មវិធីសហគមន៍ព្រៃឈើខេត្ត (មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្ត ខណ្ឌរដ្ឋបាលព្រៃឈើ អាជ្ញាធរស្រុក ឃុំ) ព្រះរាជអាជ្ញានៃអយ្យការអមសាលាដំបូងខេត្តកំពង់ធំ តំណាងបណ្តាញសហគមន៍ព្រៃឈើខេត្ត គណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើ និងអង្គការដៃគូរ គាំទ្រការគ្រប់គ្រងសហគមន៍ព្រៃឈើ។

- ប្រធានគណៈកម្មការសម្របសម្រួលកម្មវិធីសហគមន៍ព្រៃឈើខេត្ត ១នាក់
- ប្រធានសាលាដំបូងខេត្តកំពង់ធំ ១នាក់
- ព្រះរាជអាជ្ញានៃអយ្យការអមសាលាដំបូងខេត្តកំពង់ធំ ១នាក់
- មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តកំពង់ធំ ១នាក់

- មន្ទីរបរិស្ថាន ខេត្តកំពង់ធំ ១នាក់
- នាយកដ្ឋានជីវភាពសហគមន៍ អគ្គនាយកដ្ឋានសហគមន៍មូលដ្ឋាន នៃក្រសួងបរិស្ថាន (១នាក់)
- នាយកដ្ឋានព្រៃឈើ និងសហគមន៍ព្រៃឈើ រដ្ឋបាលព្រៃឈើ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (២នាក់)
- នាយកដ្ឋានពង្រឹងការអនុវត្តច្បាប់ រដ្ឋបាលព្រៃឈើ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (១នាក់)
- តំណាងបណ្តាញសហគមន៍ព្រៃឈើ គណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើ គណៈកម្មការគ្រប់គ្រងសហគមន៍តំបន់ការពារធម្មជាតិ ក្នុងខេត្តកំពង់ធំ (២៥នាក់)
- សហគមន៍តំបន់ការពារធម្មជាតិខេត្តកំពង់ធំចំនួន ៣នាក់
- តំណាងបណ្តាញសហគមន៍ព្រៃឈើខេត្ត ព្រះវិហារ ស្ទឹងត្រែង និង ក្រចេះ (៦នាក់)
- អាជ្ញាធរស្រុក ៦នាក់
- អាជ្ញាធរឃុំ ៦នាក់
- ខណ្ឌរដ្ឋបាលព្រៃឈើកំពង់ធំ(ផ្នែក និងសង្កាត់រ.ព) ១០នាក់
- ខណ្ឌរដ្ឋបាលព្រៃឈើ(ព្រះវិហារ ស្ទឹងត្រែង ក្រចេះ) ៣នាក់
- គម្រោងព្រៃឡង់បៃតង ១នាក់
- អង្គការដៃគូអនុវត្តកម្មវិធី PaFF3 នាក់ (WWF, CEPA, NTFP-EP)
- អង្គការដៃគូ AFD ១នាក់
- ក្រុមការងារ PaFF3 ថ្នាក់ខេត្ត ៤នាក់
- កម្មវិធីប្រចាំប្រទេស RECOFTC ៥នាក់

| ម៉ោង | សកម្មភាព | អ្នកទទួលខុសត្រូវ |
|---|---|---|
| ០៨:០០-៨:៣០ | ចុះឈ្មោះអ្នកចូលរួម | លោកស្រី តាន់ សេងហ៊ាន់ |
| ០៨:៣០-០៩:០០ | របាយការណ៍ស្តីពីស្ថានភាពទូទៅនៃការគ្រប់គ្រងសហគមន៍ព្រៃឈើនៅក្នុងខេត្តកំពង់ធំ | លោក ប៊ុន សុធី នាយខណ្ឌរដ្ឋបាលព្រៃឈើកំពង់ធំ |
| ០៩:០០-០៩:៣០ | មតិសំណេះសំណាល និងបើកអង្គវេទិការ | ឯកឧត្តម ព្រឹម រដ្ឋា អភិបាលរងនៃគណៈអភិបាលខេត្តកំពង់ធំ |
| ០៩:៣០-០៩:៤០ | ថតរូបជុំគ្នា | |
| ០៩:៤០-១០:០០ | សម្រាកអាហារសម្រន់ | |

| | | |
|---|---|---|
| ១០:០០-១០:៣០ | • បច្ចុប្បន្នភាពនៃការគ្រប់គ្រងសហគមន៍ព្រៃឈើនៅកម្ពុជា<br>• លិខិតបទដ្ឋានច្បាប់ គោលនយោបាយ គាំទ្រដល់ការគ្រប់គ្រងសហគមន៍ព្រៃឈើ | លោក ឡុង រតនៈកុមារ អនុប្រធាននាយកដ្ឋានព្រៃឈើ និងសហគមន៍ព្រៃឈើ នៃរដ្ឋបាលព្រៃឈើ |
| ១១:០០-១១:៣០ | សិទ្ធិ តួនាទី និងនីតិវិធីសម្រាប់សហគមន៍ព្រៃឈើចូលរួមអនុវត្តច្បាប់ ក្នុងការគ្រប់គ្រងព្រៃឈើសហគមន៍ក្រោមកិច្ចព្រមព្រៀងព្រៃសហគមន៍ | លោក អ៊ីត ភូមិរ៉ា នាយកដ្ឋាននីតិកម្ម និងពង្រឹងការអនុវត្តច្បាប់ នៃរដ្ឋបាលព្រៃឈើ |
| ១១:៣០-១២:០០ | នីតិវិធី និងតួនាទីរបស់អ្នកពាក់ព័ន្ធក្នុងការចូលរួមអនុវត្តច្បាប់ | ព្រះរាជអាជ្ញា |
| ១២:០០-១៣:៣០ | សម្រាកអាហារថ្ងៃត្រង់ | |
| ១៣:៣០-១៥:២០ | កិច្ចពិភាក្សា ស្វែងយល់អំពីការប្រឈម និងយុទ្ធសាស្ត្របង្កើនការចូលរួម ដើម្បីបន្ធូរបន្ថយនូវការប្រឈម ដោយមានការចូលរួមយោបល់ពីព្រះរាជអាជ្ញា អាជ្ញាធរ រដ្ឋបាលព្រៃឈើ បណ្តាញសហគមន៍ព្រៃឈើ<br>• សំណូមពររបស់តំណាងបណ្តាញសហគមន៍ព្រៃឈើ<br>• សំណូមពររបស់តំណាងអាជ្ញាធរមូលដ្ឋាន<br>• សំណូមពររបស់រដ្ឋបាលព្រៃឈើ | • ឯកឧត្តមប្រធានសាលាដំបូងខេត្តកំពង់ធំ<br>• លោក អ៊ិត ភូមរ៉ា<br>• លោក ឡុង រតនៈកុមារ |
| ១៥:២០-១៥:៤០ | សម្រាកអាហារសម្រន់ | |
| ១៥:៤០-១៦:០០ | បូកសរុបលទ្ធផល និងផែនការសកម្មភាព | លោក ហេង ដា |
| ១៦:០០-១៦:៣០ | ពិធីបិទអង្គវេទិការ | ឯកឧត្តម ព្រឹម រដ្ឋា អភិបាលរងនៃគណៈអភិបាលខេត្តកំពង់ធំ |